# លិខិត ពីអារាមតេហ្សេ ឆ្នាំ២០២៥

## រក្សាសេចក្តីសង្ឃឹម នៅចំកណ្តាលទីអស់សង្ឃឹម

នៅអារាមតេហ្សេក្តី ឬកន្លែងផ្សេងក្តី ពេលខ្ញុំឮយុវជននិយាយអំពីជីវិតដ៏លំបាករបស់គេ ខ្ញុំតែងតែសួរខ្លួនឯង តើពួកគេរកការពឹងផ្អែកពីអ្វីណាខ្លះ ដើម្បីឲ្យមានកម្លាំងបន្តទៅមុខទៀត? សំណួរ នេះដូចជាសង្កត់កាន់តែខ្លាំង បើសិនជាពួកគេរស់នៅក្នុងតំបន់សង្គ្រាម។

តើកម្លាំងស៊ូទ្រាំរបស់ពួកគេ ក្នុងសភាពការណ៍ដ៏សែនវេទនាទាំងអស់នោះ មកពីណា? ចំពោះខ្ញុំវិញ ខ្ញុំយល់កាន់តែច្បាស់ថា ការពឹងផ្អែកលើព្រះជាម្ចាស់ពិតជាផ្តល់សេចក្តីសង្ឃឹមដល់អ្នកដែលមានជំនឿ។ ជំនឿលើព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ គង់តែជួយគេឲ្យជឿថែមទៀតថា សេចក្តីស្លាប់មិនមែនជារឿងចុងក្រោយបង្អស់នោះទេ។

ជំនឿលើព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញនាំឲ្យពួកគេយល់ថា ទុក្ខកង្វល់ទាំងឡាយមិនអាចបង្ខាំងជីវិតទៅដល់ទិសដៅចុងក្រោយរបស់ខ្លួនបានទេ។ យើងមានវាសនាធំនិងខ្ពស់ជាងរឿងទាំងអស់នោះទៅទៀត។ នេះជាសេចក្តីសង្ឃឹម ដែលយុវជនចង់ចែកជាមួយខ្ញុំ គឺសេចក្តីសង្ឃឹមមួយនេះ ដែលហួសពីសេចក្តីសង្ឃឹមឯទៀតៗ ពីព្រោះជីវិតថ្មីអាចកើតឡើងបានសូម្បីតែពីក្នុងសភាពការណ៍ទទេសូន្យសុង ដែលគ្មានសល់អ្វីសោះឡើយ។

ព្រះនាងម៉ារីច្រៀងកោតសរសើរព្រះជាម្ចាស់ ទាំងមានចិត្តពោរពេញដោយសេចក្តីសង្ឃឹមថា៖ "ព្រះជាម្ចាស់បានសម្តែងឫទ្ធិបារមី កំចាត់មនុស្សដែលមានចិត្តឆ្មើងឆ្មៃ ទ្រង់បានទម្លាក់អ្នកកាន់អំណាចចុះពីតំណែង ហើយទ្រង់លើកតម្កើងមនុស្សទន់ទាបឡើង។ ទ្រង់បានប្រទានសម្បត្តិយ៉ាងបរិបូណ៌ ដល់អស់អ្នកដែលស្រេកឃ្លាន ហើយបណ្តេញពួកអ្នកមានឲ្យត្រឡប់ទៅវិញដោយដៃទទេ" (លូកា ១,៥១-៥៣)។ ចូរយើងហ៊ានច្រៀងជាមួយព្រះនាង

អង្វរសូមឲ្យសភាពការណ៍ទុច្ចរិតទាំងអស់នោះផ្លាស់ប្តូរមែន។ ទោះជាព្រះជាម្ចាស់ហាក់បីដូចជាស្ងៀមស្ងាត់ ក៏ផ្លូវទម្លាយអាចបើកមុខយើងភ្លាមៗដែរ។

ក្នុងពេលជាមួយគ្នា យើងត្រូវតែអធិដ្ឋាន ហើយខិតខំជួយបងប្អូន ដែលកំពុងមានទុក្ខលំបាក ជាពិសេសដោយសារសង្គ្រាម ឬការភាសខ្លួនក្រៅប្រទេស ទោះបីយើងគិតថា កិច្ចការទាំងអស់នោះតូចតាចក៏ដោយ។ តាមពិត កិច្ចការតិចតួចទាំងឡាយនេះនឹងបង្កឲ្យយើងមានចិត្តសង្ឃឹម ទោះបីយើងស្ថិតក្នុងសភាពការណ៍ងងឹតសូនសុងយ៉ាងណាក៏ដោយ។

ផលគំនិតដែលខ្ញុំយកមកចែករំលែកពេលនេះ ជាផលនៃការពិភាក្សាជាមួយយុវជនដែលរស់នៅក្នុងដំបន់មានសង្គ្រាមនាឆ្នាំកន្លងទៅ។ ខ្ញុំសូមអរគុណអស់អ្នក ដែលហ៊ានចែកនូវបទពិសោធន៍ផ្ទាល់ខ្លួន។ ពាក្យប្រឹក្សារបស់គេមានតម្លៃណាស់ ហើយជួយធ្វើឲ្យជីវិតយើងមានរបៀបត្រឹមត្រូវ។

*បងប្រុសម៉ាថាយ*

## ក្លាហានក្នុងការសង្ឃឹម

ពេលណាយើងចង់ផ្ញើខ្លួន ទៅលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ពេលនោះយើងមានបទពិសោធន៍មួយ គឺដូចជាមានអ្វីជាច្រើនប្រឆាំងនឹងសេចក្តីស្រឡាញ់នេះតែម្តង។ តាមពិតទោះបីយើងមើលឃើញអ្វីដ៏ល្អដែលមានហើយ យើងក៏ចាប់អារម្មណ៍ខ្លាំងជាង ចំពោះអ្វីទាំងប៉ុន្មាន ដែលមានកង្វះខាតនៅឡើយ។ ពេលយើងគៀបជាប់ក្នុងអារម្មណ៍បែបនេះ យើងពិបាកចិត្តណាស់។ ប៉ុន្តែអារម្មណ៍នេះហើយ ដែលបើកដួងចិត្ត ឲ្យមានសេចក្តីសង្ឃឹមថា ព្រះអង្គនឹងជួយបំពេញទាំងអស់ ឲ្យបានគ្រប់គ្រាន់។ ពេលនោះ យើងដូចជាមានសេរីភាពម្យ៉ាង។

ភាពអត់ធ្មត់ជាទីពំនឹងនៃសេចក្តីសង្ឃឹម។ គ្រីស្តទូតប៉ូលមានប្រសាសន៍ថា៖ យើងសង្ឃឹមទៅលើអ្វីដែលយើងមិនទាន់មាន (រម. ៨,២៥)។ ដូច្នេះ យើងទន្ទឹងរង់ចាំអ្វីដែលព្រះជាម្ចាស់ចង់ប្រទានឲ្យ ថ្វីត្បិតតែយើងត្រូវបន្តតស៊ូ ក្នុងសភាពការណ៍ពោរពេញដោយការភ័យខ្លាច

ផង។ ខ្លួនយើងត្រូវស្ថិតនៅកណ្តាលចន្លោះនេះ ច្រើនជាងគេចវេស រត់ចេញទៅ។

"ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏លោកអប្រាហាំនៅតែមានជំនឿ" (រម.៤,១៨)។ លោកអប្រាហាំ ជាបុព្វបុរសរបស់អ្នកជឿជាច្រើន បានពឹងផ្អែកទៅលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ដោយរបៀបមួយហួសលើសពីកម្រិតធម្មតានៃសេចក្តីសង្ឃឹម។ គាត់និងភរិយាបានទទួលអំណោយទានមួយ ដែលពួកគាត់មិនដែលសង្ឃឹមថាអាចនឹងទទួលបានសោះឡើយ។

ព្យាការីយេរេមីរស់ក្នុងសម័យសង្គ្រាម។ ខ្មាំងសត្រូវបាននិរទេសប្រជាជនឲ្យធ្វើជាឈ្លើយ ហើយគេក៏ចាប់គាត់ដាក់គុកថែមទៀត។ ប៉ុន្តែក្នុងសភាពការណ៍បែបនេះ គាត់បានសង្ឃឹមទៅលើអនាគត គឺគាត់បានទិញដីមួយឡូត៍ ពីព្រោះគាត់ជឿថា ព្រះជាម្ចាស់មិនអាចបោះបង់ប្រជាជនព្រះអង្គចោលបានឡើយ (យរ.៣២,៦-១៥)។

នៅពេលគេធ្វើកិច្ចការអស្ចារ្យរបៀបនេះ សេចក្តីសង្ឃឹមរបស់គេធ្វើឲ្យជំនឿមានភាពកាន់តែជាក់ស្តែងទៅៗ។ ជំនឿធ្វើឲ្យគេមើល នូវអ្វីដែលមិនទាន់លេចចេញនិងមិនទាន់ច្បាស់ឃើញពិតប្រាកដ។ តើយើងអាចតោងនឹងសេចក្តីសង្ឃឹមបែបនេះបាន? តាមពិត សេចក្តីសង្ឃឹមបែបនេះហើយ ដែលអាចនាំអំណរសប្បាយដល់យើងវិញ។ សូម្បីតែក្នុងសភាពការណ៍ចលាចលបំផុត អ្វីដែលយើងមិនហ៊ានទាំងសង្ឃឹមផងនោះ ក៏អាចទៅជាការជាក់ស្តែងទៅវិញ។

សព្វថ្ងៃ កិច្ចការនៃសេចក្តីសង្ឃឹមកំពុងផ្តួចផ្តើមលេចឡើង នៅក្នុងបណ្តាប្រទេសជាច្រើន ដែលរងគ្រោះព្រោះតែសង្គ្រាម។

## ស្តាប់ត្អូញនៃសេចក្តីសង្ឃឹម

ដើម្បីយល់កាន់តែច្បាស់អំពីអត្ថន័យនៃសេចក្តីសង្ឃឹម យើងត្រូវការស្តាប់មនុស្ស ដែលរស់នៅកណ្តាលទុក្ខវេទនានិងភាពឃោរឃៅ។ ព្រះជាម្ចាស់នឹងណែនាំយើង តាមរយៈពាក្យសម្តីរបស់ពួកគាត់។

ពេលខ្ញុំសួរសុខទុក្ខប្រជាជនអ៊ុយក្រែន ជាមួយបងប្រុសពីរនាក់ទៀត អ្នកណែនាំព្រះសហគមន៍មួយប្រាប់ខ្ញុំថា ៖ "ពេលអធិដ្ឋានត្រឡប់ទៅជាពេលព្យាបាល"។ ខ្ញុំឆ្ងល់មែនពេលឮ

ពាក្យសម្ដីរបស់គាត់។ គាត់បានចាប់អារម្មណ៍ថា ទោះបីស្ថិតក្នុងវិបត្តិដែលមិនចេះឈប់នោះ ប្រជាជនអាចរក្សាចិត្តសង្ឃឹម ហើយទទួលគំនិតថ្មី គឺដោយសារជីវិតខាងវិញ្ញាណ។

ជាធម្មតា ជីវិតខាងវិញ្ញាណនិងការអធិដ្ឋានមិនបង្កើតឲ្យមានផលភ្លាមៗនោះទេ ប៉ុន្តែ រួមជាមួយមធ្យោបាយដទៃ ផ្លូវនេះអាចបើកទ្វារមួយ និងផ្ដល់កម្លាំង ដែលអាចព្យាបាលមុខរបួស និងវិប្បដិសារី ព្រមទាំងប្រោសឲ្យមនុស្សលោកអាចមានសេចក្ដីសង្ឃឹមថា ពួកគេអាចជាសះស្បើយបាន។ ការអធិដ្ឋានផ្ដល់កម្លាំងឲ្យឈររឹងមាំ ក្នុងសភាពការណ៍ស្មុគស្មាញខ្លាំងជាងគេ។ ជាពិសេស ពេលសេចក្ដីងងឹតហាក់ដូចជាបានលេបអ្វីៗទាំងអស់ ការអធិដ្ឋានក៏ធ្វើឲ្យភាពអស់សង្ឃឹមរសាត់បាត់ទៅ។

ស្ដ្រីជនជាតិប៉ាលីស្ទីនម្នាក់ ដែលរស់នៅប្រទេសបារាំង ហើយដែលមានគ្រួសាររស់នៅក្រុងហ្គាសា បានសរសេរមកយើងថា៖ "សេចក្ដីស្រឡាញ់ដែលថែរក្សាជនរបួស និងអ្នកទន់ខ្សោយ ជាអ្នកផ្ដល់កម្លាំងថ្មី។ ពេលនេះ ខ្ញុំនឹកដល់អ្នកពិការដៃជើង ក្នុងព្រះគម្ពីរ ដែលមិត្តសម្លាញ់បានសែងឡើង ដោយសារតែជំនឿ។ ការអធិដ្ឋានជារបៀបមួយដើម្បីតស៊ូនិងប្រឆាំង។ សម្រាប់ខ្ញុំ រឿងនេះសំខាន់ណាស់។ ប៉ុន្តែខ្ញុំក៏ជាមនុស្សដែរ៖ ពេលបានដឹងថា បងប្អូនខ្ញុំពីរនាក់បានស្លាប់ ខ្ញុំខឹងណាស់ ខ្ញុំស្រែក ខ្ញុំយំ... ពេលស្ងប់ចិត្តវិញ ខ្ញុំដឹងថា ព្រះជាម្ចាស់នៅទីនោះដែរគឺក្នុងទុក្ខលំបាកនិងភាពអស់សង្ឃឹម។ ព្រះអង្គផ្ទាល់ជាអ្នកសែងគ្រែស្នែង និងលើកយើងឡើង"។

នារដូវក្ដៅ គាត់បានមកភូមិតេហ្សេ ពេលនោះគាត់និយាយបន្ថែមថា៖ "រាល់ព្រឹក ខ្ញុំអធិដ្ឋាន ដើម្បីរកកម្លាំង ឲ្យស្រឡាញ់ច្រើនជាងស្អប់"។ ពាក្យរបស់គាត់ដូចជាពន្លឺតាមផ្លូវយើង។

ស្ដ្រីក្មេងពីទ្វីបអាស៊ី ដែលប្រទេសរងគ្រោះដោយសង្គ្រាម ប្រាប់យើងថា៖ "ប្រជាជនយើងលែងដឹងថាត្រូវធ្វើអ្វីហើយ ប៉ុន្តែគេរកសេចក្ដីសុខសាន្តក្នុងព្រះគម្ពីរដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ដ"។ តាមប្រវត្តិសាស្ត្រ យើងដឹងថា ប្រជាជនអ៊ីស្រាអែលត្រូវភៀសខ្លួន ជាច្រើនដង ប៉ុន្តែទោះជាយ៉ាងណា ក្នុងបរិបទដ៏សែនវេទនាទាំងនោះ ពួកគេនៅតែអាចបង្កើតសហគមន៍របស់គេ។ ព្រះជាម្ចាស់មានគម្រោងការណ៍អស្ចារ្យសម្រាប់យើង តែយើងត្រូវដើរមួយជំហានម្ដងៗ។ អ្នកណាដែលយកចិត្តទុកដាក់នឹងជីវិតពេលបច្ចុប្បន្ន អ្នកនោះបង្ហាញថា ជីវិតនោះជាអំណោយ ដែលរាល់វេលាត្រូវគេទទួលនិងរស់យ៉ាងពេញលេញ។ ពេលយើងអធិដ្ឋាន យើង

ភ្ជាប់ខ្លួនជាមួយប្រភពនៃសេចក្តីសុខសាន្ត ដែលឲ្យយើងមានកម្លាំង លើកទឹកចិត្តគ្នាទៅវិញទៅមក ហើយយល់ពីតម្លៃនៃការចែករំលែក និងការសាមគ្គីផង"។

ខ្ញុំឮម្នាក់ពីប្រទេសលីបង់និយាយថាៈ "ម្តាយខ្ញុំជាគំរូអំពីសេចក្តីសង្ឃឹម។ គាត់បានឆ្លងកាត់ទុក្ខលំបាកជាច្រើន ប៉ុន្តែគាត់នៅតែឈរ ! បើថ្ងៃនេះ ខ្ញុំនៅទីនេះ ពោរពេញដោយកម្លាំង គឺដោយសារគាត់។ គាត់បានអប់រំយើងឲ្យចេះអធិដ្ឋាន និងផ្ញើជីវិតទៅលើព្រះជាម្ចាស់។ មនុស្សដែលរស់ដោយជំនឿ ក៏សម្តែងជំនឿ ពីព្រោះគេផឹកពីជំនឿនេះនៅប្រភពវា ហើយគេអាចក្លាយទៅជាសាក្សី"។

តើសាក្សីនៃសេចក្តីសង្ឃឹម ដែលយើងអាចជួបនិងស្តាប់ ដើម្បីបំភ្លឺក្នុងសភាពការណ៍ផ្ទាល់ខ្លួន ជានរណា? ចូរយើងបើកត្រចៀករបស់យើង ហើយស្តាប់អ្វីដែលគេនិយាយ។

## តស៊ូក្នុងសេចក្តីសង្ឃឹម

តើយើងត្រូវមានប្រតិកម្មយ៉ាងណា ពេលគម្រោងការណ៍ផ្ទាល់ខ្លួនមិនអាចទៅមុខរួច ហើយពេលសេចក្តីសង្ឃឹមរលាយបាត់សូន្យ? ព្រះយេស៊ូផ្តល់ពន្លឺ ឲ្យយើងទៅជាប្រជាជននៃសេចក្តីសង្ឃឹមរហូត។

ថ្ងៃមួយ ព្រះអង្គជួបមហាជន ជាមនុស្សស្រេកឃ្លាន។ ព្រះអង្គអាណិតអាសូរគេពន់ពេកណាស់។ តាមពាក្យក្នុងគម្ពីរ មានសរសេរថា "ចិត្តព្រះអង្គចេញទៅរកគេ" ជាមូលហេតុដែលទ្រង់ក៏រករបៀបមួយ ដើម្បីតបឆ្លើយនឹងសេចក្តីត្រូវការរបស់គេ។

ពេលយើងមិនព្រមចុះចាញ់ក្នុងកាលៈទេសៈមានវិបត្តិ ពេលនោះហើយដែលសេចក្តីសង្ឃឹមលេចឡើងនៅក្នុងចិត្តយើង។ ចលនានេះផ្ទុយនឹងការរង់ចាំធ្វើពើ គឺយើងត្រូវតែតស៊ូ គ្មានផ្លូវផ្សេងនោះទេ។ មានតែសេចក្តីសង្ឃឹមនេះ ដែលអាចនាំយើងឆ្លង ពីអ្វីដែលមនុស្សអាចធ្វើបាន ទៅកាន់អ្វីដែលព្រះជាម្ចាស់អាចធ្វើបាន។

សេចក្តីសង្ឃឹមទៅលើព្រះយេស៊ូគ្រីស្តបើក ឲ្យយើងឃើញខ្លះៗ អំពីអនាគតយ៉ាងល្អពេញលេញ ដែលព្រះជាម្ចាស់បានរៀបចំឲ្យយើង។ សេចក្តីសង្ឃឹមនេះដូចជាយុថ្ការបស់កប៉ាល់

ដែលថ្លក់យើងយ៉ាងជាប់ នៅពេលខ្យល់ព្យុះ។ ដូច្នេះ យើងអាចសម្តែងភាពស្មោះត្រង់ ដល់ការត្រាស់ហៅរបស់ខ្លួន (ចំពោះកិច្ចការជាកាតព្វកិច្ចរបស់ខ្លួន) និងដល់អស់អ្នកដែលយើងរួមរស់ជាមួយ។ សេចក្តីសង្ឃឹមជាម្ចូកដែក ដែលការពារយើងពីទុក្ខលំបាក ដែលចេះតែធ្លាក់មកលើយើងផង។

វិន័យអារាមនៅភូមិតេហ្សេរំឭកយើងថា កុំឲ្យចាញ់ "រឿងអាស្រូវនៃការបែកបាក់រវាងនិកាយក្នុងគ្រីស្តសាសនា។ ទោះបីគ្រីស្តបរិស័ទប្រកាសថា ត្រូវតែចេះស្រឡាញ់គ្នាទៅវិញទៅមកដូចបងប្អូន ក៏ពួកគេនៅតែបែងចែកពីគ្នាជាក្រុមៗ"។ ចំពោះបងប្រុស រ៉ូហ្សេរ៍៖ ឯកភាពក្នុងគ្រីស្តសាសនាជាផ្លូវមួយ ដើម្បីណែនាំមនុស្សលោកទៅកាន់សន្តិភាព។

## រក្សាលក្ខណៈរបស់ខ្លួនជាប្រជាជននៃសេចក្តីស្រឡាញ់

ក្នុងសភាពការណ៍ ដែលមនុស្សមិនចេះយល់គ្នា សេចក្តីសង្ឃឹមអាចរលាយយ៉ាងចាប់រហ័ស។ ពេលជួបនឹងបរិយាកាសប្រកបដោយការសង្ស័យ មនុស្សជាច្រើនអាចជាប់ក្នុងអួននៃការមិនទុកចិត្តគ្នាដែរ។

រឿងនេះអាចកើតមានឡើង ក្នុងសមាគម ក្រុម ឬគ្រួសារ ក៏ដូចជាក្នុងសង្គមនិងប្រទេស ជួនកាលតាមរបៀបលាក់កំបាំង ជួនកាលតាមរបៀបបើកចំហ។ ទោះជាយ៉ាងណារឿងនេះនឹងស៊ីកម្លាំងយើងយ៉ាងខ្លាំង។ ដូច្នេះម្តងៗ ពេលជួបជាមួយអយុត្តិធម៌ យើងត្រូវតែបរិហារអំពើអាក្រក់ កុំឲ្យមានមនុស្សទៅជាជនរងគ្រោះនៃអ្នកដទៃទៀត។

ដើម្បីរក្សាសេចក្តីសង្ឃឹម យើងត្រូវការគ្នាទៅវិញទៅមក។ សេចក្តីសង្ឃឹមរីកចម្រើននៅពេលដែលយើងយកចិត្តទុកដាក់នឹងតម្រូវការគ្នា។ យើងអាចឃើញក្នុងពេលមានវិបត្តិ គង់តែមានមនុស្សខ្លះដែលសុខចិត្តរស់ ញញឹម ហើយចែកទ្រព្យសម្បត្តិរបស់គេបន្តិចបន្តួច ជារៀងរាល់ថ្ងៃ។

សេចក្តីសង្ឃឹមទាក់ទងជាមួយសេចក្តីពិត និងយុត្តិធម៌ ពីព្រោះគុណធម៌ទាំងបីនេះជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។ យើងអាចទស្សនាគុណធម៌ទាំងនោះបានក្នុងជីវិត សេចក្តីស្លាប់ និង

ការរស់ឡើងវិញ របស់ព្រះយេស៊ូ។ ដើម្បីថែទាំសេចក្តីសង្ឃឹម យើងត្រូវតែទល់មុខនឹងភាពជាក់ស្តែងនៃការរស់នៅរបស់ខ្លួន ហើយពិនិត្យមើល ប៉ុន្តែដោយប្រើពន្លឺនៃព្រះបន្ទូលសន្យារបស់ព្រះអង្គ។

យុវជនម្នាក់រស់នៅក្នុងតំបន់សង្គ្រាមពន្យល់មកខ្ញុំថា៖ "ខ្ញុំនៅក្នុងហាងកាហ្វេ អានសៀវភៅ។ ស្រាប់តែមានគ្រាប់បែកផ្ទុះនៅគ្រប់ទីកន្លែង។ មនុស្សរត់ពាសពេញ ដោយសារភ័យខ្លាច។ រីឯខ្ញុំវិញ ខ្ញុំសម្រេចចិត្តបន្តអានសៀវភៅដល់ចប់។ ប្រហែល ទៅរកទីជម្រកដើម្បីការពារខ្លួន ប្រសើរជាង ប៉ុន្តែពេលនោះ កាយវិការរបស់ខ្ញុំនេះចង់សម្តែងសេចក្តីសង្ឃឹម និងប្រឆាំងជាមួយសង្គ្រាមដែលមិនអាចជៀសរួចបានទេ។

បងប្រុសម្នាក់ក្នុងអារាមមានយោបល់ថា៖ "សេចក្តីសង្ឃឹមជាប្រតិកម្ម ហើយលើសពីនេះទៅទៀត វាភាតត្បាត។ ពាក្យផ្ទុយនឹងពាក្យ"សង្ឃឹម" គឺពាក្យ"ការមិនអើពើ"ឬ"ការចុះចាញ់"។ ពេលខ្ញុំទៅទស្សនាប្រទេសខ្ញុំ ដែលកំពុងមានសង្គ្រាមដែរ ខ្ញុំឃើញមុខមនុស្ស ព្រួយ ថប់បារម្ភ និងតានតឹង។ ខ្ញុំសួរខ្លួនឯងថា៖ តើអាចធ្វើអ្វីបាន? ពេលនោះខ្ញុំមានគំនិតមួយ គឺពេលខ្ញុំបើកបរឡាន ខ្ញុំនឹងប្រយ័ត្នឲ្យមែនទែននឹងមនុស្សដែលមកពីមុខខ្ញុំ និងឲ្យគេមានអាទិភាពលើខ្ញុំវិញ។ កាយវិការតូចនេះស៊ីពេលប្រហែល៥វិនាទី ប៉ុន្តែខ្ញុំឃើញតឹកមុខគេ ធូរស្រាលឬញញឹមបន្តិច នាំឲ្យទុក្ខលំបាករបស់គេក៏បានស្រាលបន្តិចដែរ។

អ្វីៗទាំងអស់ក្នុងខ្លួនយើងប្រឆាំងនឹងសង្គ្រាមនិងមរណភាព ហើយអ្វីៗទាំងអស់ចង់បានតែជីវិតនិងសោភ័ណភាព។

## សេចក្តីសង្ឃឹមនៃបុណ្យចម្លង

តើពេលនេះខ្ញុំនៅឯណា? តើខ្ញុំនៅជើងព្រះឈើឆ្កាង ដូចនៅថ្ងៃសុក្រពិសិទ្ធ ឬកំពុងឋិតនៅក្នុងអំណរនៃព្រឹកថ្ងៃបុណ្យចម្លង ឬមួយទៀត រង់ចាំទាំងធីងើលមិនដឹងទៅណា ដូចនៅថ្ងៃសៅរ៍ពិសិទ្ធ ?

នៅកន្លែងដែលខ្ញុំនៅ តើខ្ញុំអាចមើលច្រកឆ្លងមួយប្រកបដោយសេចក្តីសង្ឃឹមឬ? ច្រក

នោះបើកមកនៅមុខខ្ញុំ ពេលណាខ្ញុំរំពៃមើលព្រះយេស៊ូ ដែលបានបូជាជីវិត ព្រោះតែព្រះអង្គស្រឡាញ់មនុស្សលោក។ ធម៌មេត្តាករុណារបស់ព្រះអង្គមានកម្លាំងខ្លាំងជាងអំណាចឃោរឃៅទាំងឡាយ និងខ្លាំងជាងការស្អប់និងសេចក្តីស្លាប់ទៀត។

សេចក្តីសង្ឃឹមមិនកើតមកពីការត្រួតពិនិត្យអំពីសភាពការណ៍នោះទេ គឺជាផលផ្លែនៃការទុកចិត្តតូចមួយទៅវិញ។ ការទុកចិត្តតូចនេះភ្លឺញាប់ញ័រ ក្នុងយប់អន្ធការ ដូចកាលពីដើម ចំពោះមិត្តសម្លាញ់របស់ព្រះយេស៊ូ។ ពួកគេភាគច្រើនបានបោះបង់ព្រះអង្គចោល នៅពេលលោកពីឡាតកាត់ក្តី។ មានតែសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលផ្តល់ឲ្យពួកគេមានកម្លាំងត្រឡប់មករកព្រះអង្គវិញ។

យើងចង់មើលព្រះយេស៊ូមានជីវិតថ្មីប្រកបដោយសិរីរុងរឿងពិតមែន ! ក៏ប៉ុន្តែ វត្តមានរបស់ព្រះអង្គមិនស្រេចទៅលើការមើលឃើញឬការមើលមិនឃើញនោះទេ។ ជួនកាល សេចក្តីអស់ សង្ឃឹមរបស់យើងបង្កឲ្យយើងខ្វាក់ភ្នែក ដូចនាងម៉ារីពីភូមិម៉ាដាឡា នៅផ្នូរព្រះយេស៊ូ។ ព្រះអង្គសួរនាងថា៖ "ហេតុអ្វីនាងយំដូច្នេះ? តើនាងកំពុងរកអ្វី?" (លូកា២០,១៥)។ សំណួរទីពីររំឭកពាក្យដំបូងរបស់ព្រះយេស៊ូចំពោះសាវ័កពីរនាក់ ដែលមកតាមក្រោយព្រះអង្គថា៖ "តើអ្នកទាំងពីរមករកអ្វី?" (យ៉ូហាន ១,៣៨)។ ពេលព្រះយេស៊ូស្គាល់ទុក្ខលំបាកនិងសេចក្តីស្លាប់យ៉ាងវេទនាបំផុត តម្រូវការសម្រាប់អត្ថន័យប្រែប្រួលទៅជាបំណងប្រាថ្នាមួយ គឺចង់បានភាពស្និទ្ធស្នាលនឹងអ្នកដទៃ។

ពេលយើងផុតពីសេចក្តីស្លាប់ ហើយមានជីវិតរស់ឡើងវិញ ព្រះយេស៊ូក៏ទាក់ទាញយើងឲ្យមករស់នៅជិតនឹងព្រះអង្គ។ ទោះជាចិត្តយើងពោរពេញដោយរឿងអ្វី ជាការព្រួយបារម្ភក្តី ឬអំណរសប្បាយក្តី ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញនាំយើង ឲ្យមានទំនាក់ទំនងជាមួយព្រះបិតា និងឲ្យរួបរួមគ្នាជាមួយអ្នកដទៃ ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ ដូច្នេះយើងមិនជាប់គុកក្នុងភាពអស់សង្ឃឹមរបស់ខ្លួនទៀតទេ គឺជីវិតថ្មីអាចចាប់ផ្តើមលេចឡើងបាន។

សន្តប៉ូលសរសេរថា៖ "សេចក្តីសង្ឃឹមមិនធ្វើឲ្យយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង" (រម.៥,៥)។ ចូរយើងរស់ដោយពឹងលើសេចក្តីស្រឡាញ់នេះ។ សូមព្រះវិញ្ញាណ

ដ៏វិសុទ្ធណែនាំយើងរហូត!

## សេចក្ដីសង្ឃឹមនិងសន្តិភាពជម្រុញយើងឲ្យដើរ

ជំនឿទៅលើព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញបានជួយមនុស្សជាច្រើន ឲ្យសង្ឃឹម សូម្បីតែនៅចំកណ្ដាលនៃវិបត្តិ។ ព្រះអង្គអាចនាំយើងឲ្យធ្វើដំណើរទៅ ហួសពីដែនកំណត់របស់ខ្លួន ដូចជាប្រទានឲ្យចិត្តយើងទៅរកអ្នកដទៃ ហើយព្រមធ្វើការងារយ៉ាងសកម្ម។

ដើម្បីជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ យើងត្រូវការមានចិត្តក្លាហាននិងហ៊ាន។ មានន័យថា គឺតស៊ូមែនទែន កុំឲ្យសេចក្តីស្លាប់និងហឹង្សាឃោរឃៅ ដែលមានជុំវិញខ្លួនធ្វើឲ្យយើងគាំង ក៏លែងមានកម្លាំងធ្វើអ្វីក៏ដោយ។

ព្រះជាម្ចាស់អាចប្រោសធ្វើឲ្យសភាពការណ៍ហាក់បីអស់សង្ឃឹម ត្រឡប់ទៅជាសភាពការណ៍ថ្មីស្រឡាង ល្អបំផុត។ ព្រះអង្គដែលអាចបង្កើតជីវិតឲ្យផុសពីសេចក្តីស្លាប់ ក៏អាចធ្វើឲ្យការលើកលែងទោសដល់គ្នាលេចចេញពីជម្លោះផងដែរ។

នៅពេលព្រឹកថ្ងៃអាទិត្យ ដែលព្រះអម្ចាស់យេស៊ូមានព្រះជន្មរស់ឡើងវិញ ស្ត្រីដែលជាមិត្តរបស់ព្រះអង្គទៅដល់ផ្នូរ ហើយសួរគ្នាថា៖ "តើអ្នកណានឹងប្រមៀលថ្មឲ្យយើង?" (មក.១៦,៣)។ តើក្នុងជីវិតយើង មានថ្មអ្វី ដែលយើងត្រូវសូមព្រះជាម្ចាស់ជួយប្រមៀលជូន ដើម្បីឲ្យយើងមានជីវិតថ្មី?

ជីវិតថ្មីនេះអាចធ្វើឲ្យយើងឈររួច ហើយចាប់ផ្ដើមធ្វើដំណើរជាមួយអ្នកដទៃ។ យើងក្លាយជាអ្នកធ្វើដំណើរ (បូជនីយេសក៍) ដើម្បីចែកសេចក្ដីសង្ឃឹម ដែលមានក្នុងចិត្ត ជូនដល់មនុស្សឯទៀតៗ។ ដំណើររបស់យើងក៏ដើម្បីចែកសន្តិភាពដែរ ពីព្រោះ"ព្រះគ្រីស្តជាសន្តិភាពរបស់យើង" (អភ.២,១៤)។ តើយើងឮព្រះសូរសៀងខ្សឹបថា៖ "ខ្ញុំទុកសេចក្តីសុខសាន្តឲ្យអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់ឲ្យនេះមិនដូចសេចក្តីសុខសាន្តដែលមនុស្សលោកឲ្យទេ។ ចូរកុំរន្ធត់ចិត្តកុំភ័យខ្លាចឲ្យសោះ (យហ.១៤,២៧-២៨)។

បើយើងចង់ទៅជាអ្នកធ្វើដំណើរដើម្បីចែកសន្តិភាព យើងត្រូវយល់ថា គ្មានសន្តិភាពពិត

ប្រាកដជាវាបណាគ្មានយុត្តិធម៌រួមជាមួយ។ យើងមានសន្តិភាពក្នុងចិត្ត ក៏មកពីយើងរស់ដោយមានសេចក្តីសង្ឃឹមដែរ ហើយគុណធម៌ទាំងពីរនេះបូកជាមួយគ្នា ដើម្បីផ្តល់ឲ្យយើងបានសេរីភាពខាងផ្លូវវិញ្ញាណថែមទៀត។ ពេលព្រះវិញ្ញាណដ៏វិសុទ្ធណែនាំយើង សេរីភាពនេះប្រោសឲ្យយើងមានកម្លាំង ដើម្បីស្រឡាញ់ជីវិតផង និងប្រឆាំងនឹងអយុត្តិធម៌ផង។

ប្រហែល ថ្ងៃណាមួយ យើងនឹងច្រៀងបទរបស់លោកតាសាការី។ គាត់ជាមនុស្សចាស់ជរា រស់នៅលើទឹកដីដែលសាសន៍ដទៃកាន់កាប់។ គាត់ត្រេកអរសប្បាយ ព្រោះតែកំណើតកូនដែលមិនបានរំពឹងទុក។ គាត់ច្រៀងថា៖ "ព្រះរបស់យើងមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ ព្រះអង្គប្រទានថ្ងៃរះពីស្ថានលើមក ដើម្បីរំដោះយើង និងដើម្បីបំភ្លឺអស់អ្នកដែលស្ថិតនៅក្នុងទីងងឹតក្រោមអំណាចនៃសេចក្តីស្លាប់ ព្រមទាំងតំរង់ផ្លូវយើង ឆ្ពោះទៅរកសេចក្តីសុខសាន្ត" (លូកា ១,៧៨-៧៩)។

តើយើងព្រមត្រៀមខ្លួន ដើម្បីសង្ឃឹម នៅចំកណ្តាលទីអស់សង្ឃឹម?